<u>ឯកសារសម្រាប់ចុះក្នុងគេហទំព័រអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍</u>

កាលពីព្រឹកថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស លើកទី៥ ប្រចាំឆ្នាំ២០១៦ ក្រោមការដឹកនាំរបស់ ឯកឧត្តម វេជ្ជបណ្ឌិត **តែង គន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការ អញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និង អន្តរជាតិ ចំនួន៣៦រូប។ <u>ក្នុងកិច្ចប្រជុំនោះផ្តោតសំខាន់ទៅលើ</u>៖

-របាយការណ៍សកម្មភាព ដែលបានអនុវត្តក្នុងខែកន្លងមក

-បទបង្ហាញពីផែនការថវិកាជាតិសម្រាប់ទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍

-បទបង្ហាញពីគំនិតផ្តួចផ្តើមការឆ្លើយតបមេរោគអេដស៍តាមរយៈដៃគូសហគមន៍ ចំពោះក្រុមប្រឈមមុខខ្ពស់(MCPI)

-បទបង្ហាញពីការប៉ាន់ប្រមាណក្នុងការចំណាយទៅលើការងារអេដស៍ថ្នាក់ជាតិ (NASA)

-និងការបង្ហាញពីសកម្មភាពទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍




